# ការចិញ្ចឹមគោជាលក្ខណៈគ្រួសារ

## សេចក្តីផ្តើមៈ

ការចិញ្ចឹមគោជាលក្ខណៈគ្រួសារចាំបាច់យើងត្រូវដឹងពីបច្ចេកទេសនៃការចិញ្ចឹមដើម្បីជួយថែរក្សាគោឱ្យមានសុខភាពល្អ និងជួយជាកម្លាំងអូសទាញសម្រាប់ប្រើប្រាស់ឱ្យបានយូរអង្វែង ព្រោះគោជាសត្វមានប្រយោជន៍ដ៏សំខាន់ដូចជាៈ

- ជាកម្លាំងអូសទាញក្នុងការងារកសិកម្ម
- ផ្តល់សាច់ និង ទឹកដោះសម្រាប់ជាអាហារ និង ជម្រុញការលូតលាស់របស់សារពាង្គកាយ
- សម្រាប់ផលិតកូន និង ទុកបន្តពូជ
- ផ្តល់លាមកសម្រាប់យកទៅធ្វើជាជីកំប៉ុស្ដិ៍សម្រាប់ដាក់ស្រែចំការ ដំណាំផ្សេងៗដើម្បីបង្កើនទិន្នផល
- ផ្តល់ជាស្បែកសម្រាប់ធ្វើឧបករណ៍ផ្សេងៗ ដូចជា កាតាប ស្បែកជើង ខ្សែព្រ័ត្រធ្វើស្គរធំជាដើម ។
- ជាពិសេសពេលថ្មីនេះ គេយកលាមកគោលាយជាមួយទឹក រួចបញ្ចូលបង្កន់ជីវឧស្ម័ន ដើម្បីយកឧស្ម័នសម្រាប់ដុតចំអិនអាហារ ។

ដើម្បីឱ្យការចិញ្ចឹមគោទទួលបានជោគជ័យ យើងត្រូវយកចាប់អារម្មណ៍លើចំណុចសំខាន់មួយចំនួនដូចជាៈ

- ជម្រក ឬ ក្រោល
- ការជ្រើសរើសពូជ
- ចំណី និង ការផ្តល់ចំណី
- ការថែទាំ និងការការពារជម្ងឺ
- ជម្ងឺ និង ការព្យាបាល

## ១. សំណង់ក្រោល ឬ ជម្រកៈ

- ទីកន្លែងៈ ត្រូវសង់នៅលើដីទួល មានខ្យល់អាកាសចេញចូល និង ស្រួលបង្ហូរទឹក ហើយត្រូវនៅ ក្រោមខ្យល់ដើម្បីកុំឱ្យធុំក្លិន ។
- ទិសៈ ត្រូវសង់ក្រោលគោ-ក្របី បណ្តោយថ្ងៃ ។
- របៀបសង់ៈ កម្រាលក្រោលត្រូវមានចំណោទដើម្បីងាយស្រួលបញ្ចេញទឹក
    - ផ្ទៃក្រឡាៈ

- គោ ក្របី ញី ៤ ម² ក្នុង ១ ក្បាល
- មេ គោ ក្របី បំបៅកូនៈ ៨-៩ ម² ក្នុង ១ ក្បាល
- កូនគោ ក្របីៈ ២-២.៥ ម² ក្នុង ១ ក្បាល

❖ កម្ពស់ក្រោលៈ
  - គោ ក្របី ឈ្មោលៈ ១.៤-១.៦ ម² ក្នុង ១ ក្បាល
  - គោ ក្របី ញីៈ ១-១.២ ម² ក្នុង ១ ក្បាល។

- ត្រូវមានទ្រុងសម្រាប់ដាក់ស្មៅ ចំបើងដើម្បីទុកឱ្យគោ ក្របី ស៊ីបន្ថែម (បណ្តោយៈ ១.៥ម៉ែត្រ ទទឹងៈ ១ម៉ែត្រ កម្ពស់ៈ ០.៥ម៉ែត្រ) ត្រូវមានរណ្តៅរី រោងសម្រាប់ដាក់លាមក សង់ឱ្យឆ្ងាយពីក្រោល (បណ្តោយៈ ៤ម៉ែត្រ ទទឹងៈ ២ម៉ែត្រ កម្ពស់ៈ០.៧ម៉ែត្រ)។



## ២. ការជ្រើសរើសពូជគោ

- អំពីរូបរាងៈ មានមាឌធំ មានភាពរហ័សរហួន ស្លូត។
- ផ្នែកដទៃទៀតៈ
  - ក្បាលៈ ធំល្មមតែវែង ថ្ងាស់ទូលាយ មាត់ទូលាយ ច្រមុះសើម ស្លឹកត្រចៀកធំល្មម ធ្មេញសស្មើជិត គ្មានប្រេះស្រាំ ស្នែងស្មើ។

- ក និងដងខ្លួនៈ កវែងល្មម ទ្រូងទូលាយ ស្មាទូលាយ ខ្នងវែងត្រង់ ឬកោងឡើងលើបន្តិច ឆ្អឹងជំនីរធំមូល គូទទូលាយ។
- ជើងៈ ជើងទាំងបួនធំត្រង់ ជើងមុខទាំងពីរឃ្លាតត្រង់គ្នា ក្បាលជង្គង់មូល ភ្លៅក្រោយទាំងពីរធំវែង ក្រចកជើងជិតរឹងមាំ។
- កន្ទុយៈ ធំ
- ស្បែកៈ រលោង ស្តើងល្មម រោមរាបជាប់ស្បែក
- ប្រដាប់បន្តពូជៈ
    - គោ ក្របី ឈ្មោល មានពងទាំងពីរធំស្មើ
    - គោញីៈ ក្រសោមដោះធំ សរសៃឈាម លើដោះលេចចេញច្បាស់ ក្បាលដោះធំស្មើ ឃ្លាតពីគ្នា។



កន្សោមដោះធម្មតា



ពងស្វាសដែលមានទម្រង់ល្អ

**២-១-អាយុរបស់គោះ**

យើងអាចប៉ាន់ស្មានអាយុគោបានច្បាស់នៅពេលវាមានអាយុ ១៨ ខែឡើងទៅដោយសម្គាល់តាមរយៈការផ្លាស់ប្តូរធ្មេញរបស់វាដែលមានចំនួន ៨ នៅផ្នែកខាងមុខ និងជួរក្រោម។ គោមានធ្មេញពីរប្រភេទ គឺធ្មេញទឹកដោះ និងធ្មេញចាស់ (ធ្មេញបន្ទាស់)។ ធ្មេញចាស់ ឬធ្មេញបន្ទាស់ដុះជំនួសធ្មេញទឹកដោះម្តងពីរៗ ដោយផ្តើមចេញពីចន្លោះកណ្តាលទៅ ហើយមានទំហំធំជាងធ្មេញទឹកដោះ។



- ពេលអាយុ ១៨ខែ វាមានធ្មេញចាស់ ២ ដុះនៅចន្លោះកណ្តាលធ្មេញទឹកដោះចំនួន ៦។
- ពេលអាយុ ២ឆ្នាំ វាមានធ្មេញចាស់ ៤ ដុះនៅចន្លោះកណ្តាលធ្មេញទឹកដោះចំនួន ៤។
- ពេលអាយុ ៣ឆ្នាំ វាមានធ្មេញចាស់ ៦ ដុះនៅចន្លោះកណ្តាលធ្មេញទឹកដោះចំនួនន ២។
- ពេលអាយុ ៤ឆ្នាំ វាមានធ្មេញចាស់ ៨។
- អាយុលើសពី ១០ ឆ្នាំ



**២-២-ការជ្រើសរើសមេគោសម្រាប់បន្តពូជះ**

- មានរូបរាងស្អាត សុខភាពល្អ
- មេគោត្រូវមានសុខភាពល្អ មានជើងមាំ ឈរត្រង់ពេលមើលពីចំហៀង ពីមុខ និងពីក្រោយ។ ពេលដើរត្រូវនៅលើខ្សែត្រង់ទៅមុខ មិនត្រូវជើងវៀចចេញ ឬវៀចចូលឡើយ។ គោដើរជើងវៀចអាចឱ្យគោងាយសិកក្រចកហើយក្លាយជាដំបៅ។ ក្រចកគោត្រូវស្របគ្នា មិនត្រូវញែកចេញពីគ្នាឡើយ។
- មានដោះល្អ មានចុងដោះស្មើល្អគ្រប់ទាំងបួន ។ចំពោះគោយកទឹកដោះត្រូវមានកន្សោមដោះធំ
- តាមធម្មតាមេគោអាចបន្តពូជបាននៅពេលដែលវាមានអាយុពី ២,៥ ទៅ ៣ ឆ្នាំ។
- មេគោរៀបរកឈ្មោលត្រូវថែរក្សាឱ្យបានល្អ និង ផ្តល់ចំណីឱ្យបានគ្រប់គ្រាន់។

**២-៣-ការជ្រើសរើសគោបាដើម្បីបង្កាត់៖**

- ត្រូវជ្រើសរើសគោបាដែលមានប្រវត្តិពូជល្អ មានជើងមាំ និងក្រចកល្អ។
- ត្រូវជ្រើសរើសគោបាដែលមានពងស្វាសទំហំស្មើគ្នា ហើយមានអាយុយ៉ាងតិច ៣ ឆ្នាំឡើងទៅ។
- ត្រូវជ្រើសរើសគោបាធំ តែកុំឱ្យធំជាងមេគោពេក ពិសេសចំពោះមេគោកូនដំបូង។
- ត្រូវពិនិត្យឱ្យបានច្បាស់លាស់តើគោនោះធាត់ពេក ឬស្គមពេក?